# សាវតារ និងស្នាព្រះហស្តព្រះបាទសូរ្យវរ្ម័នទី១

អ្នកប្រវត្តិវិទូជាច្រើនលើកឡើងថា បន្ទាប់ពីព្រះបាទជ័យវរ្ម័នទី៥ ចូលទិវង្គតទៅ ស្រុកទេសពុំមានសន្តិភាពឡើយ ដ្បិតថាសង្គ្រាមដណ្តើមអំណាចបានកើតឡើងបង្កដោយភាគីចំនួនបីក្រុមផ្សេងគ្នា រួមមាន ព្រះបាទឧទ័យទិត្យវរ្ម័នទី១ ព្រះបាទជ័យវីរវរ្ម័ន និងព្រះបាទសូរ្យវរ្ម័នទី១។ នៅដំណាក់កាលចុងក្រោយ អ្នកដែលឈ្នះសង្គ្រាមនេះ គឺព្រះបាទសូរ្យវរ្ម័នទី១ នៅរវាងចន្លោះឆ្នាំ ១០០៦ ដល់ ១០១០ នៃគ.ស.។ តើព្រះរាជាអង្គនេះ មានខ្សែស្រឡាយខាងណា? មានស្រុកកំណើតនៅទីណា? មានព្រឹត្តិការណ៍នយោបាយសំខាន់ៗអ្វីខ្លះ? និងមានស្នាព្រហស្តសំខាន់ៗបែបណាខ្លះ?

## សាវតារ និងស្រុកកំណើត

ប្រវត្តិវិទូដំបូង ដូចជា លោក George Coedès និងលោក L.P. Briggs យល់ថា ព្រះបាទសូរ្យវរ្ម័នទី១ គឺជាចម្បាំងរាតទីទឹកដីមួយអង្គដែលយាងមកពីឧបទ្វីបម៉ាឡេស៊ី ដ្បិតលោកទាំងពីរបានសិក្សាសិលាចារឹកជាច្រើនក្នុងរជ្ជកាលរបស់ទ្រង់ និងយល់ស្របគ្នាថា គោរម្យងារ "កំតួន" របស់ព្រះរាជាអង្គនេះមានជាពាក្យក្នុងភាសាម៉ាឡេស៊ី ដែលពាក្យ "តួន" (តួន) ប្រែថា "លោកម្ចាស់"។[១] ក្រោយមកទើបលោក George Coedès បានដឹងថាពាក្យ "កំតួន" ជាពាក្យខ្មែរបុរាណដែលចង់បញ្ជាក់អំពីការបន្តទាយាទខាងស្រី (តោន, តួន ដែលត្រូវនឹងពាក្យខ្មែរទំនើបថា "ដូន")។ ចំណែក លោកស្រី Madelian Giteau លើកឡើងថា ព្រះបាទសូរ្យវរ្ម័នទី១ មានជាតិកំណើតពីម៉ាឡេនៅតាមដងទន្លេមេណាមត្រង់តំបន់លពបុរី និងជាព្រះរាជបុត្រនៃព្រះរាជាមួយអង្គនៃអាណាចក្រម៉ាឡេស៊ី។[២]

ក្រោយមក លោក Michael Vickery បានសិក្សាបន្ថែមអំពីសិលាចារឹកជាច្រើននៅក្នុងរាជ្យរបស់ទ្រង់ ហើយបានធ្វើសេចក្តីសន្និដ្ឋានជាថ្មីថា ព្រះអង្គទំនងជាមនុស្សនៅក្នុងគ្រួសារអភិជន ឬគ្រួសារមានអំណាចណាមួយ ដែលមានប្រវត្តិចាស់ជាងគ្រួសារដែលទើបមានសកម្មភាពចាប់ពីរាជ្យព្រះបាទជ័យវរ្ម័នទី២ (K.136) ហើយព្រះអង្គទំនងមានស្រុកកំណើតនៅតំបន់ខាងត្បូង ឬឦសានតំបន់អង្គរ (ក្រចេះ ត្បូងឃ្មុំ កំពង់ចាម កំពង់ធំ)។[៣] ប៉ុន្តែគំនិតនេះលោក Claude Jacques មិនយល់ស្របនោះឡើយ ដោយលោកគិតថា ព្រះបាទសូរ្យវរ្ម័នទី១ ទំនងមានស្រុកកំណើតនៅក្រុងសម្ពុបុរ (ខេត្តក្រចេះ) ដោយលោកយោងទៅលើការសិក្សាសិលាចារឹក K.125 រកឃើញនៅសំបូរ

[១] Briggs 1951.

[២] Giteau 1974.

[៣] Vickery 1985.

ខេត្តក្រចេះ (តាកឹង) ដែលរៀបរាប់អំពីមន្ត្រីម្នាក់ដែលជាអ្នកគោរពនិងស្ថិតនៅក្រោមអំណាចរបស់ព្រះបាទសូរ្យវរ្ម័នទី១ (ព្រះកម្រតេងអញបរមបពិត្រ) នៅក្នុងគ.ស.១០០១។ ទោះបីជាយ៉ាងណាលោក Michael Vickery បានប្រឆាំងគំនិតនេះទាំងស្រុង ដោយយល់ថា សិលាចារឹក K.125 គ្រាន់តែបញ្ជាក់អំពីកាលបរិច្ឆេទដំបូងៗដែលចារឹកដោយមន្ត្រីរៀបរាប់អំពីស្តេចរបស់ខ្លួន ដែលមិនមែនជាលក្ខណៈផ្លូវការរបស់ស្តេចឡើយ ហើយវាមានលក្ខណៈដូចនឹងសិលាចារឹកជាច្រើនទៀត ដូចជាសិលាចារឹកប្រាសាទរបងរមាស K.153 ក្នុងខេត្តកំពង់ធំដែលចារឹកតាំងពីគ.ស.១០០០ និងសិលាចារឹកជាច្រើនទៀតដូចជា សិលាចារឹកនៅដីក្រែង K.468 សិលាចារឹកនៅកំពង់ចាម K.89 សិលាចារឹក K.161 (គ.ស.១០០១-១០០៣)។ ម៉្វោះហើយ លោក Vickery យល់ថា សិលាចារឹកនៅខេត្តក្រចេះខាងលើមិនអាចជាតឹកតាងរឹងមាំដែលអាចនិយាយថា ទ្រង់មានស្រុកកំណើតនៅទីនោះឡើយ។

ដោយឡែកសិលាចារឹកមួយទៀតរកឃើញនៅប្រាសាទទួលតាពេជ្រ ខេត្តកំពង់ធំ K.834 រៀបរាប់ថា៖ "ព្រះបាទសូរ្យវរ្ម័នទី១ មានកំណើតក្នុងគ្រួសារចេះដឹងជ្រៅជ្រះផ្នែកប្រពៃណីទំនៀមទម្លាប់ទ្រង់មានគតិបណ្ឌិតពី ប្រតទ៌ន ទិលិប និងចំណេះដឹងជ្រៅជ្រះដូចព្រះអង្គមុនៗដែរ"។[៤] ម្យ៉ាងវិញទៀតសិលាចារឹកប្រាសាទព្រះធាតុទឹកឆា K.702 បានបញ្ជាក់ថា៖ "ទ្រង់ជាអ្នកដែលប្រសូត្រចេញពីខ្សែស្រឡាយខាងមាតានៃព្រះបាទស្រីឥន្ទ្រវរ្ម័ន ដោយសារតែទ្រង់មានប្រកពចេញពីរាជវង្សនេះហើយទើបទ្រង់ត្រូវទទួលបានរាជបល្ល័ង្កបន្តពីក្សត្រាស្តេចមុនៗ"។[៥] តែទោះបីយ៉ាងណាអ្នកប្រវត្តិវិទូជាច្រើនយល់ថា គាថានេះគ្រាន់តែជារឿងមួយដែលអ្នកចារចង់លើកសរសើរព្រះរាជាដ្បិតគេគិតថាទ្រង់មិនមែនជាខ្សែរាជវង្សឡើយ។

## ព្រឹត្តិការណ៍នយោបាយសំខាន់ៗ

រឿងរ៉ាវដ៏ពិសេសមួយដែលគេដឹងថា នៅគ.ស.១០១១ នៅពេលដែលព្រះអង្គបានឈ្នះសង្គ្រាមជាស្ថាពរហើយ ទ្រង់បានឱ្យគេចារសិលាចារឹកយ៉ាងវែង ដែលនិយាយពីពាក្យសម្បថរបស់មន្ត្រីតាមខេត្តនីមួយៗ ចារឹកនៅប្រាសាទភិមានអាកាស និងប្រាសាទឃ្លាំង (K.292, K.466-468, K.551-552)។ ក្នុងនោះមានឃ្លាមួយនៃសម្បថបានសរសេរថា៖ "នឹងមានភក្តីភាពតែចំពោះព្រះអង្គតែមួយគត់ បើនរណាហ៊ានក្បត់ សូមឱ្យធ្លាក់ទៅដល់ស្ថាននរក ដរាបណាលែងមានព្រះចន្ទ្រ និងព្រះអាទិត្យ"។[៦]

[៤] Coedès, 1953.

[៥] Coedès, 1953.

[៦] Coedès, 1952.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ក្នុងរជ្ជកាលរបស់ព្រះបាទសូរ្យវរ្ម័នទី១ ទ្រង់បានពង្រីកវិសាលភាពទឹកដីអង្គរទៅកាន់តែឆ្ងាយៗ ដូចសិលាចារឹកមួយនៅលពបុរី (ស្រុកសៀមបច្ចុប្បន្ន) ក៏មានរៀបរាប់អំពីទ្រង់ដែរ ហើយចំណែកនៅក្នុងសិលាចារឹកសម្បថវិញមាន "ម្រតាញ" មួយចំនួនមកពីស្រុកនៅប្រមាណល្វោ (ប្រមាណ អាចត្រូវនឹងខេត្តសព្វថ្ងៃ រីឯតំបន់ល្វោ ស្ថិតនៅខាងជើងអយុធ្យា រាជធានីថៃសម័យក្រោយអង្គរ)។ លោក Vickery បានសិក្សាសិលាចារឹកជាច្រើននៅសម័យមុនអង្គរ ហើយបានបញ្ជាក់ឱ្យដឹងថា ការពង្រីកវិសាលភាពទឹកដីរបស់ព្រះបាទសូរ្យវរ្ម័នទី១ ពុំមែនមានន័យថា ខ្មែរទៅឈ្លានពានទឹកដីជនជាតិសៀមនោះទេ ព្រោះតំបន់នោះជាទឹកដីខ្មែរកាលពីបុរាណ ដែលមានកស្តុតាងតាំងពីស.វ.ទី៧ ក្នុងរាជ្យព្រះបាទឦសានវរ្ម័នទី១ដែលគេដឹងថាបុត្រារបស់ទ្រង់ព្រះនាម "សីវទត្ត" គឺជាអ្នកដឹកនាំឬចៅហ្វាយខេត្តនៅទីនោះ។[៧]

## ព្រះមហេសី ព្រះញាតិវង្ស មន្ត្រី និងព្រះបរមមរណនាម

អ្នកប្រវត្តិវិទូយល់ថា ព្រះបាទសូរ្យវរ្ម័នទី១ មានព្រះមហេសីជាច្រើនអង្គ ហើយមហេសីសំខាន់ៗរបស់ទ្រង់មានព្រះនាងវីរលក្ស្មី និងព្រះនាងទ្ធបតីន្ទ្រលក្ស្មីៗ តាមរយៈសិលាចារឹក K.660 ផ្តល់ពត៌មានឱ្យដឹងថា ព្រះនាងវីរលក្ស្មី មានត្រកូលបន្តពីព្រះបាទស្រីហស៌វរ្ម័នទី១តាមខ្សែស្រឡាយខាងម្តាយ ដែលមានន័យថា ព្រះនាងជាប់ខ្សែលោហិតជាមួយស្តេចអង្គមុនៗគឺព្រះបាទយសោវរ្ម័នទី១ និងព្រះបាទហស៌វរ្ម័នទី១ៗ ប៉ុន្តែលោក Coedès បញ្ជាក់ថា ព្រះនាងជាអតីតមហេសីរបស់ព្រះរាជាអង្គមុន គឺព្រះបាទជ័យវីរវរ្ម័ន ម៉្លោះហើយទើបលោកស្រី Madelian Giteau សន្និដ្ឋានថា ព្រះបាទសូរ្យវរ្ម័នទី១ រៀបអភិសេកជាមួយព្រះនាងដើម្បីឱ្យគេទទួលស្គាល់អំណាចរបស់ទ្រង់ៗ ចំណែក ទិន្នន័យបានពីសិលាចារឹកប្រាសាទបេងឱ្យដឹងថា ព្រះនាងទ្ធបតីន្ទ្រលក្ស្មី ដែលជាមហេសីមួយអង្គទៀតរបស់ទ្រង់ គឺជាប្អូនស្រីមន្ត្រីជាន់ខ្ពស់មួយរូបមាននាមថា ទ្ធបតីន្ទ្រវរ្ម័ន ហើយក៏ត្រូវជាមហេសីរបស់ព្រះបាទជ័យវីរវរ្ម័នដូចគ្នាដែរ។

ព្រះបិតា និងព្រះមាតារបស់ទ្រង់ គេពុំស្គាល់ថាជានរណាពិតប្រាកដឡើយ ហើយចំណែកឯបុត្ររបស់ទ្រង់គឺគេស្គាល់ព្រះនាមថា "ឧទ័យទិត្យវរ្ម័ន"ៗ ព្រះរាជគុរុឈ្មោះ "យោគិស្វរបណ្ឌិត" និង "កវិស្វរបណ្ឌិត" ព្រះរាជបុរោហិតឈ្មោះ "សិវចារ្យ", "កិតិន្ទ្របណ្ឌិត" និង "ជយេន្ទ្របណ្ឌិត", រីឯព្រះហោតរឈ្មោះ "សង្ករៈ"ៗ មន្ត្រីសំខាន់ៗផ្សេងទៀតមានឈ្មោះ "សិវវិន្ទុ (ត្រូវជាចៅសិវចារ្យ"ៗ ព្រះអង្គសោយទិវង្គតនៅឆ្នាំ១០៤៩ ដោយមានមរណនាមថា "បរមនិព្វានបទ"ៗ

---

[៧] Vickery, 2001-2002.

អត្ថបទដោយៈ ម៉ង់ រ៉ាលី

## ស្នាព្រះហស្ត

*ដោយហេតុថា ព្រះបាទសូរ្យវរ្ម័នទី១ គឺជាស្តេចដែលជឿទៅលើព្រហ្មញ្ញសាសនា និកាយព្រះឥសូរ យើងឃើញថាសំណង់ប្រាសាទភាគច្រើនរបស់ទ្រង់ ច្រើនតែឧទ្ទិសដល់ព្រះឥសូរ។ ប្រាសាទដែលកសាងឡើងក្នុងរាជ្យរបស់ទ្រង់មានដូចជា ផ្នែកជាច្រើននៃប្រាសាទព្រះវិហារ (ស្រីសិខារេស្វរ) ប្រាសាទភ្នំជីសូរ (សូរ្យទ្រី ឬ សូរ្យបព៌ត) (រូបលេខ១) ប្រាសាទវត្តបាសែត (ស្រីជ័យក្សេត្រ) ប្រាសាទវត្តឯកភ្នំ (នវេន្ទ្រគ្រាម) (រូបលេខ២) ប្រាសាទឃ្លាំងខាងជើងនិងខាងត្បូង (រូបលេខ៣) ប្រាសាទភិមានអាកាស (រូបលេខ៤) ផ្នែកខ្លះនៃប្រាសាទវត្តភូ (រូបលេខ៥) ផ្នែកខ្លះនៃបាកាណ (រូបលេខ៦) ក្លោងទ្វាររាជវាំង (រូបលេខ៧) ប្រាសាទភ្នំជើងព្រៃ (រូបលេខ៨) ប្រាសាទស្រីគ្រប់លក្ខណ៍ ប្រាសាទស្នឹងខាងកើតនិងខាងលិច (រូបលេខ៩-១០) ប្រាសាទចៅស្រីវិបុល (រូបលេខ១១) ប្រាសាទរបងរមាស (រូបលេខ១២-១៣) ប្រាសាទមឿងតាំ ប្រាសាទបន្ទាយស្រី ដំដែក។ល។ ស្ថាបត្យកម្មទាំងនេះគេបានចាត់ថ្នាក់បញ្ចូលទៅក្នុងសិល្បៈចុងរចនាបថបន្ទាយស្រី ដល់រចនាបថបាភួន។[៨] ក្រៅពីសំណង់ស្ថាបត្យកម្មដែលជាស្នាព្រះហស្តដ៏ច្រើនសន្ធឹកសន្ធាប់នេះវិញ ទ្រង់បានកសាងអាងស្តុកទឹកដ៏ធំមួយធំជាងគេបង្អស់នៅខាងលិចអង្គរ មានប្រវែង ៨គ.ម. គុណនឹង ២.២គ.ម. ដែលក្រោយមកក្នុងរាជ្យព្រះបាទឧទ័យទិត្យវរ្ម័នទី២ បានកសាងបន្ថែម និងសាងប្រាសាទមេបុណ្យខាងលិចនៅចំកណ្តាល។*

*ជារួមមក ព្រះបាទសូរ្យវរ្ម័នទី១ គឺជាព្រះរាជាមួយអង្គដែលទំនងប្រសូត្រចេញពីគ្រួសារអភិជនមួយនៅឦសានតំបន់អង្គរ (កំពង់ធំ កំពង់ចាម ក្រចេះ) ហើយបានធ្វើសង្គ្រាមប្រឆាំងជាមួយព្រះបាទជ័យវីរវរ្ម័នដោយជោគជ័យទើបទ្រង់អាចឡើងសោយរាជ្យបាន។ នៅក្នុងរជ្ជកាលព្រះអង្គទ្រង់បានពង្រីកវិសាលភាពទឹកដីទៅកាន់តែឆ្ងាយពីរាជធានីអង្គរ និងបានកសាងស្នាព្រះហស្តជាច្រើនជាពិសេស គឺសំណង់ប្រាសាទក្នុងរាជ្យរបស់ព្រះអង្គនៅក្នុងទឹកដីប្រទេសកម្ពុជាមានច្រើនរាប់មិនអស់។ ប្រសិនបើមើលតាមការដឹកនាំ និងស្នាព្រះហស្ត គេអាចចាត់ទុកព្រះអង្គ គឺជាមហាក្សត្រដ៏ឆ្នើមបំផុតមួយនៅក្នុងប្រវត្តិសាស្ត្រខ្មែរ៕*

---

[៨] Boisselier 1966.

# ឯកសារយោង


**Boisselier, Jean**

1966, "*Asie du Sud-Est, Le Cambodge* ", Tome I, Paris.

**Briggs, Lawrence Palmer**

1951, "*The ancient Khmer empire*", New York.

**Coedès, George**

1952, *Inscription du Cambodge*, Vol IV, Hanoi.

1953, *Inscription du Cambodge*, Vol V, Hanoi.

**Giteau, Madelein**

1974, *Histoire d' Angkor*, Paris.

**Vickery, Michael**

1985, The reign of Suryavarman I and royal factionalism at Angkor, *Journal of southeast Asian Studies*, Vol 16, No 2, September.

2001, *Summary of lectures given at the Faculty of Archaeology, Royal University of Fine Arts*, Phnom Penh.


AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION



រូបលេខ១៖ ប្រាសាទភ្នំជីសូរ ខេត្តតាកែវ



រូបលេខ២៖ ប្រាសាទវត្តឯកភ្នំ ខេត្តបាត់ដំបង

អត្ថបទដោយ៖ ម៉ង់ វាលី



រូបលេខ២៣៖ ប្រាសាទឃ្លាំងខាងត្បូង ខេត្តសៀមរាប



រូបលេខ២៤៖ ប្រាសាទភិមានអាកាស ខេត្តសៀមរាប

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៥៖ ប្រាសាទភិមាយ ប្រទេសឡាវ



រូបលេខ២៦៖ ផ្នែកខ្លះនៃក្រុមបាកាណ ខេត្តព្រះវិហារ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



*រូបលេខ៧៖ ក្លោងទ្វាររាជវាំងក្រុងអង្គរធំ ខេត្តសៀមរាប*



*រូបលេខ៨៖ ប្រាសាទភ្នំដើងព្រៃ ខេត្តកំពង់ចាម (រូបថត៖ ថៃ ឈាងម៉េង)*

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៩៖ ប្រាសាទស្ទឹងខាងកើត ខេត្តបាត់ដំបង



រូបលេខ១០៖ ប្រាសាទស្ទឹងខាងលិច ខេត្តបាត់ដំបង

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១១៖ ប្រាសាទចៅស្រីវិបុល ខេត្តសៀមរាប



រូបលេខ១២៖ ប្រាសាទបេងមាស ខេត្តកំពង់ធំ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៣៖ ប្រាសាទរបង់រមាស ខេត្តកំពង់ធំ

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី